**ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វៀ**
**ការិយាល័យទំនាក់ទំនងជាមួយ មាតាបិតា ក្រុមគ្រួសារ សហគមន៍**
**និងការសហការជាមួយក្រុមសាសនា**
440 NORTH BROAD STREET SUITE 114
PHILADELPHIA, PENNSYLVANIA 19130

JAMES W. SCOTT — ទូរស័ព្ទ៖ ២១៥-៤០០-៦៣៨៤
ប្រធាន — ទូរសារ៖ ២១៥-៤០០-៤១៨១

ថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១១

ជូនចំពោះមាតាបិតា និងអាណាព្យាបាល៖

ភ្ជាប់ជាមួយលិខិតនេះលោកអ្នកនិងទទួល ច្បាប់ Title I ដែលជាច្បាប់ស្តីពីការចូលរួមរបស់មាតាបិតាទូទាំងក្រសួង។

**តើ Title I ជាអ្វី?**
Title I គឺជាមាត្រានៃច្បាប់ ពីដើមហៅថា "ច្បាប់មិនបន្សល់ក្មេង (No Child Left Behind)" ដែលបានយល់ព្រមដោយសភាក្នុងឆ្នាំ ២០០២។ ច្បាប់នេះមានបទបញ្ញាសម្រាប់សាលារដ្ឋ ដែលជា សាលាបឋមសិក្សា និងវិទ្យាល័យ អំពីប្រធានបទដូចជា ការប្រើថវិការបស់រដ្ឋសហព័ន្ធ ការហ្វឹកហ្វឺនគ្រូបង្រៀន ជោគជ័យក្នុងការសិក្សា សិទ្ធិរបស់មាតាបិតា ការអប់រំសិស្សពិការ និងសិទ្ធិស្មើភាពគ្នាផ្នែកអត្តពលកម្ម។

**តើច្បាប់ Title I ដែលជាច្បាប់ស្តីពីការចូលរួមរបស់មាតាបិតាទូទាំងក្រសួង ជាអ្វី?**
ច្បាប់នេះចែងពីវិធីដែលក្រសួងអប់រំនឹងធ្វើយ៉ាងណាឲ្យមាតាបិតាអាចមានតួនាទីដែលមានអត្ថន័យក្នុងការអប់រំរបស់កូនខ្លួន និងពីវិធីរៀបចំសកម្មភាពដើម្បីឲ្យមាតាបិតាចូលរួម នៅគ្រប់ការិយាល័យ។ សាលារបស់ក្រសួងនីមួយៗដែលទទួលប្រាក់ជំនួយ Title I សម្រាប់សិស្សក្រីក្រ ត្រូវមានការយល់ព្រមពីការចូលរួមរបស់មាតាបិតា នៃច្បាប់នេះ។

ច្បាប់របស់ក្រសួងយើង បានបង្កើតឡើងដោយមានការផ្តល់យោបល់ពីសំណាក់មាតាបិតា។ ក្នុងចំណោមអ្វីៗផ្សេងទៀត គឺការស្នើសុំឲ្យផ្តល់ព័ត៌មានទៅមាតាបិតាឲ្យទាន់ពេលវេលា ជាភាសាផ្សេងៗ ផ្តល់ឱកាសអប់រំដើម្បីយល់ដឹងអំពី កម្មវិធីសិក្សា ការប្រឡង និងអ្វីៗផ្សេងទៀត តាមរយៈកម្មវិធីមាតាបិតាជាដៃគូដែលមានសិទ្ធិស្មើភាពគ្នា (PREP)។ កែលម្អនូវវិធីបញ្ចូលយោបល់របស់មាតាបិតាទៅក្នុងផែនការ (ការកែលម្អ) នៃការអនុវត្តន៍ របស់សាលា តាមរយៈក្រុមប្រឹក្សាសាលា (SACs) ហើយដើម្បីបង្កើន និងធ្វើឲ្យគណកម្មការមាតាបិតា Title I ទូទាំងក្រសួង មានលក្ខណៈចម្រុះ ខុសប្លែកៗគ្នា។

**ហេតុអ្វីបានជាច្បាប់នេះមានសារៈសំខាន់ដល់លោកអ្នក?**
ច្បាប់នេះជម្រាបលោកអ្នកអំពី ការផ្តល់ដំណឹង និងព័ត៌មាន ដែលមាតាបិតា និងអាណាព្យាបាលមានសិទ្ធិត្រូវដឹង សកម្មភាពរបស់ សាលា និងក្រសួងណាខ្លះ ដែលតម្រូវឲ្យមានការផ្តល់យោបល់ពី មាតាបិតា និងអាណាព្យាបាល វិធានការអ្វីដែលក្រសួងត្រូវធ្វើដើម្បីបំបាត់ឧបស័គ្គដែលរារាំងមិនឲ្យមាតាបិតា និងអាណាព្យាបាលចូលរួមបាន តើការសហការអ្វីខ្លះ ដែលក្រសួងនឹងធ្វើជាមួយ សមាគមមាតាបិតានិងសាលា និងអង្គការមាតាបិតាជាច្រើនទៀត។ ការឆ្លើយតបរបស់ មាតាបិតា និងអាណាព្យាបាល ទៅនឹងច្បាប់នេះ នឹងត្រូវបញ្ជូនជាមួយច្បាប់នេះទៅ ក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា។

យើងខ្ញុំសង្ឃឹមថា លោកអ្នកនឹងសហការជាមួយការិយាល័យរបស់យើងខ្ញុំ ដើម្បីគាំទ្រដល់សាលារបស់កូនលោកអ្នក។ ***គិតដល់ភាពរុងរឿង៖ គិតដល់មាតាបិតា និងសាលា សហការគ្នាដើម្បីបង្កើនជោគជ័យក្នុងការសិក្សារបស់សិស្ស។***

ដោយសេចក្តីស្មោះស្ម័គ្រ

JAMES W. SCOTT
ប្រធាន
ការិយាល័យទំនាក់ទំនងជាមួយ មាតាបិតា ក្រុមគ្រួសារ
សហគមន៍ និងការសហការជាមួយក្រុមសាសនា